ធនាគារកម្ពុជាសាធារណៈ

កិច្ចព្រមព្រៀងសមាជិកប័ណ្ណឥណពន្ធ/ប័ណ្ណអេធីអឹម

VISA/MASTERCARD LIFESTYLE /PROPRIETARY ធនាគារកម្ពុ

សូមថ្លែងអំណរគុណចំពោះការ ស្នើសុំប្រើប្រាស់ប័ណ្ណ Visa/Mastercard/ប័ណ្ណអេធីអឹម Proprietary ធនាគារកម្ពុ។ ចំណុចសំខាន់សម្រាប់លោក-លោកស្រី សូមលោក-លោកស្រីអានដោយយកចិត្តទុកដាក់អំពីកិច្ចព្រមព្រៀងសមាជិកប័ណ្ណដូចមានចែងខាងក្រោម មុនពេលលោក-លោកស្រីប្រើប្រាស់ប័ណ្ណ Visa/Mastercard/ប័ណ្ណអេធីអឹម Proprietary ធនាគារកម្ពុ។ តាមរយៈការប្រើប្រាស់ប័ណ្ណនេះ លោក-លោកស្រីយល់ព្រមទទួលយកខ និងលក្ខខណ្ឌដូចមានចែងខាងក្រោម ហើយយល់ព្រមអនុវត្តតាមខ និងលក្ខខណ្ឌទាំងនោះ។

ធនាគាររក្សាសិទ្ធិកែប្រែ បន្ថែម ឬធ្វើវិសោធនកម្មខ និងលក្ខខណ្ឌដែលមានក្នុងកិច្ចព្រមព្រៀងនេះ ឬកែប្រែកម្រៃ និងសោហ៊ុយដែលត្រូវបង់នៅពេលណាមួយ ហើយការកែប្រែនេះត្រូវអនុវត្តនៅថ្ងៃមានប្រសិទ្ធភាពដែលកំណត់ដោយធនាគារដោយមិនមានការជូនដំណឹង។ ក្នុងករណីលោក-លោកស្រីមិនយល់ស្របទៅនឹងការកែប្រែ ការបន្ថែម និង/ឬការធ្វើវិសោធនកម្ម លោក-លោកស្រីត្រូវ ប្រគល់ប័ណ្ណ ដែលកាត់ ជាពីរផ្នែកមកធនាគារ ឬ ជូនដំណឹងជាលាយលក្ខណ៍អក្សរ ហើយបំផ្លាញ/ លុបឥរិប នៅលើប័ណ្ណ នេះចោល។ ក្នុងករណីធនាគារមិនបានទទួលប័ណ្ណដែលកាត់ជាពីរផ្នែក ឬការជូនដំណឹងជាលាយលក្ខណ៍អក្សរ ត្រូវចាត់ទុកថាលោក-លោកស្រីយល់ព្រមទទួលយកការកែប្រែ ការបន្ថែម និង/ឬការធ្វើវិសោធនកម្ម។

ការបន្តប្រើប្រាស់ប័ណ្ណរបស់លោក-លោកស្រី ត្រូវបានចាត់ទុកថាជា ការទទួលយករបស់លោក-លោកស្រីនូវរាល់ការកែប្រែ ការបន្ថែម និង/ឬការធ្វើវិសោធនកម្ម។

សូមលោក-លោកស្រីពិនិត្យមើលខ និងលក្ខខណ្ឌដែលគ្រប់គ្រងការប្រើប្រាស់ប័ណ្ណ និងការជូនដំណឹងរបស់ធនាគារតាមរយៈគេហទំព័រប៉ុស្តិ៍ធនាគារ www.campubank.com.kh។

គ្រប់គ្រងប័ណ្ណរបស់លោក-លោកស្រីដោយយកចិត្តទុកដាក់

តួនាទីរបស់សមាជិកប័ណ្ណគឺការពារប័ណ្ណឥណទានពីការក្លែងបន្លំ។ ខាងក្រោមនេះគឺជាវិធានការការពារ៖

- ចាត់ទុកប័ណ្ណរបស់លោក-លោកស្រីដូចជាប្រាក់គ្រប់ពេល។
- ចុះហត្ថលេខាលើប័ណ្ណដោយប្រើទឹកថ្នាំដែលមិនអាចលុបបានភ្លាមៗ នៅពេលលោក-លោកស្រីទទួល ប័ណ្ណ ហើយកាត់ប័ណ្ណដែលហួសកាលកំណត់ជាពីរ បើមិនដូច្នោះទេត្រូវធានាថា ឥរិបនៅលើប័ណ្ណត្រូវបានលុបចេញ/បំផ្លាញ។
- នៅពេលកំណត់លេខសម្គាល់អត្តសញ្ញាណបុគ្គល (PIN) សូមកុំប្រើប្រាស់ថ្ងៃខែឆ្នាំកំណើត លេខអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន លេខប័ណ្ណបើកបរ ឬលេខទំនាក់ទំនង។

- សូមកុំសរសេរលេខ PIN នៅលើប័ណ្ណរបស់លោក-លោកស្រីដើម្បីជៀសវាងការដកសាច់ប្រាក់ដែលមិនមានការអនុញ្ញាតពីម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ (អេធីអឹម) ព្រមទាំងដើម្បីជៀសវាងការធ្វើប្រតិបត្តិការដែលមិនមានការអនុញ្ញាត។
- មិនត្រូវអនុញ្ញាតឱ្យនរណាម្នាក់ប្រើប្រាស់ប័ណ្ណរបស់លោក-លោកស្រីឡើយ។
- សូមរក្សាលេខប័ណ្ណ និង PIN ប្រកបដោយការសម្ងាត់គ្រប់ពេលវេលា។
- ប្រសិនបើលោក-លោកស្រីសង្ស័យថា ការសម្ងាត់លេខ PIN របស់លោក-លោកស្រីត្រូវបានគេស្គាល់ សូមបង្កើតលេខ PIN ថ្មីភ្លាម។ ដើម្បីជៀសវាង/បង្ការការធ្វើប្រតិបត្តិការដែលមិនមានការអនុញ្ញាតណាមួយ។
- មិនត្រូវទុកចោលប័ណ្ណដែលហួសកាលកំណត់នៅកន្លែងគ្មានសុវត្ថិភាព។
- ត្រូវធានាថាប័ណ្ណរបស់លោក-លោកស្រីទុកចោលដោយគ្មានការយកចិត្តទុកដាក់។
- សូមយកចិត្តទុកដាក់ចំពោះប័ណ្ណ មិនថាប័ណ្ណនោះនៅក្នុងកាបូបលុយ កាបូបស្ពៃយ ថតតុ ឬនៅបេឡា ធិការ ជាពិសេសនៅពេលប័ណ្ណនេះនៅឆ្ងាយពីលោក-លោកស្រី។
- សូមជូនដំណឹងមកធនាគារ ប្រសិនបើលោក-លោកស្រីធ្វើដំណើរទៅកាន់បរទេស។
- នៅពេលទិញទំនិញ សូមធានាថាប្រតិបត្តិការត្រូវបានដំណើរការនៅចំពោះមុខលោក-លោកស្រី។
- នៅពេលបេឡាធិការប្រគល់ប័ណ្ណរបស់លោក-លោកស្រីមកវិញ ត្រូវប្រាកដថាវាជាប័ណ្ណរបស់លោក-លោកស្រី ហើយថាវាមិនត្រូវបានក្លែងបន្លំក្នុងទម្រង់ណាមួយ។
- សូមកុំចុះហត្ថលេខានៅត្រង់ blank charge slip។ បុគ្គលដែលមានគំនិតទុច្ចរិតអាចទាញយកផលប្រយោជន៍ពីកន្លែងដែលនៅទំនេរដើម្បីបន្ថែមចំនួនទឹកប្រាក់។
- សរុបវិក្កយបត្រទូទាត់ដើម្បីប្រាកដថា មានតែចំនួនទឹកប្រាក់សម្រាប់ថ្លៃទំនិញ/សេវាកម្មដែលបានទិញតាមរយៈការប្រើប្រាស់ប័ណ្ណរបស់លោក-លោកស្រី និងចំនួនទឹកប្រាក់ផ្សេងទៀតដែលលោក-លោកស្រីយល់ព្រមទូទាត់ជូនដៃគូអាជីវកម្មដែលអាចរាប់បញ្ចូលទាំងលុយទឹកតែ មុនពេលចុះហត្ថលេខាលើវិក្កយបត្រ ទូទាត់។
- រក្សាវិក្កយបត្ររបស់លោក-លោកស្រីសម្រាប់ផ្ទៀងផ្ទាត់ជាមួយរបាយការណ៍របស់លោក-លោកស្រី។
- របាយការណ៍គណនីរបស់លោក-លោកស្រីមានព័ត៌មានសំខាន់ ហេតុដូច្នេះ សូមរក្សាទុករបាយការណ៍នោះនៅកន្លែងមានសុវត្ថិភាព។
- សូមជូនដំណឹងមកធនាគារ ក្នុងករណីមានប្រតិបត្តិការមិនបានដឹងណាមួយត្រូវបានកត់ត្រានៅក្នុង របាយការណ៍គណនីរបស់លោក-លោកស្រី។
- កិនកំទេចចោលរបាយការណ៍ចាស់ៗ (រាប់បញ្ចូលទាំងគណនីដែលត្រូវបានបិទ) ជាមុនសិនមុនពេលឈប់ប្រើប្រាស់ប័ណ្ណ។
- មិនត្រូវបង្ហាញព័ត៌មានប័ណ្ណឥណពន្ធទៅបុគ្គលណាម្នាក់ដែលផ្សព្វផ្សាយលក់តាមទូរស័ព្ទ។
- លោក-លោកស្រីផ្តល់អត្តសញ្ញាណប័ណ្ណ និងព័ត៌មានប័ណ្ណតែទៅភាគីដែលលោក-លោកស្រីផ្តើមទំនាក់ទំនងមុនប៉ុណ្ណោះ។
- ធនាគារនឹងមានលេខគណនីរបស់លោក-លោកស្រី។ ប្រសិនបើលោក-លោកស្រីទទួលទូរស័ព្ទពីភាគីណាមួយដែលអះអាងថាជាធនាគារកម្ពុជាសាធារណៈ និងអ្នកហៅទូរស័ព្ទនោះស្នើសុំលេខគណនីរបស់លោក-លោកស្រី សូមកុំផ្តល់តាមការស្នើសុំនោះឱ្យសោះ។
- សូមជូនដំណឹងមកធនាគារនៅពេលមានការផ្លាស់ប្តូរអាសយដ្ឋាន ដើម្បីជៀសវាងការផ្ញើប័ណ្ណថ្មីទៅកាន់អាសយដ្ឋានចាស់។

- ប្រសិនបើប័ណ្ណត្រូវចោរលួច ឬបាត់ សូមជូនដំណឹងមកធនាគារចេញផ្សាយជាបន្ទាន់។
- សូមរក្សាលេខទំនាក់ទំនងរបស់ផ្នែក E-Banking/ATM និងផ្នែកសេវាបម្រើអតិថិជនតាមខ្លួនជានិច្ច។
- សូមឆ្លើយតបភ្លាមៗចំពោះការជូនដំណឹងអំពីប្រតិបត្តិការរបស់ធនាគារដែលបានផ្ញើទៅកាន់លោក-លោកស្រីតាម SMS ឬតាមអ៊ីម៉ែល ក្នុងករណីលោក-លោកស្រីមិនអនុញ្ញាតចំពោះប្រតិបត្តិការនោះ។
- លោក-លោកស្រីត្រូវទទួលខុសត្រូវចំពោះការចាត់វិធានការបង្ការនានាដើម្បីធានាថា កុំព្យូទ័រប្រើប្រាស់ផ្ទាល់ខ្លួន និងឧបករណ៍ឆ្លាតវ័យរបស់លោក-លោកស្រីគ្មានមេរោគគ្រប់ពេលវេលា។

ម៉ោងប្រតិបត្តិការ

សមាជិកប័ណ្ណត្រូវប្រើប័ណ្ណដើម្បីធ្វើប្រតិបត្តិការទូទាត់ណាមួយ ឬការដកសាច់ប្រាក់នៅដៃគូអាជីវកម្មដែលទទួលបានសិទ្ធិអនុញ្ញាត និង/ឬតាមរយៈម៉ាស៊ីនអេធីអឹម/ម៉ាស៊ីនដកដាក់ប្រាក់ ស្របតាមម៉ោងប្រតិបត្តិការស្តង់ដារ ២៤ ម៉ោងក្នុងមួយថ្ងៃ ប្រាំពីរថ្ងៃក្នុងមួយសប្តាហ៍ម៉ោងក្នុងស្រុក។

ផ្នែក E-Banking/ATM និងផ្នែកសេវាបម្រើអតិថិជន
ប័ណ្ណដែលបានបាត់

ចំពោះប័ណ្ណដែលបានបាត់ ឬចោរលួច សូមទូរស័ព្ទមកកាន់លេខ (៨៥៥)-២៣ ៩៩៨ ៨៩៦/៤២៨ ១០០, (៨៥៥)-១០/១២ ៤២៨ ១០០ ឬទៅកាន់សាខាធនាគារកម្ពុជាសាធារណៈដែលនៅជិតបំផុត ឬបណ្តាញសាច់ប្រាក់ងាយស្រួល/សមាជិកប្រព័ន្ធ Cambodian Shared Switch (CSS) (ប្រសិនបើនៅក្នុងប្រទេសកម្ពុជា) សមាជិក Visa / Mastercard (ប្រសិនបើនៅក្រៅប្រទេស) ដើម្បីដាក់របាយការណ៍។ ត្រូវរាយការណ៍អំពីការបាត់ ឬចោរលួចប័ណ្ណភ្លាមៗ។ ប្រសិនបើលេខ PIN របស់លោក-លោកស្រីត្រូវបានគេស្គាល់ សូមលោក-លោកស្រីរាយការណ៍អំពីបញ្ហានេះភ្លាមៗ។ សម្រាប់ព័ត៌មានលម្អិត សូមមើលប្រការ ៣ នៃកិច្ចព្រមព្រៀងសមាជិកប័ណ្ណ។

ខ និងលក្ខខណ្ឌ
១. និយមន័យ

១.១ ក្នុងកិច្ចព្រមព្រៀងនេះ លៃកលែងតែមានចែងផ្សេងពីនេះ៖

១. "គណនី" សំដៅលើគណនីសន្សំ ឬគណនីចរន្តរបស់ធនាគារកម្ពុជាសាធារណៈដែលបានបើកដោយឈ្មោះសមាជិកប័ណ្ណជាឯកត្តបុគ្គល ឬរួមគ្នាជាមួយភាគីម្ខាងទៀត ដែលគណនីសន្សំ/គណនី ចរន្តតម្រូវឱ្យមានទឹកប្រាក់គ្រប់គ្រាន់ដើម្បីឱ្យសមាជិកប័ណ្ណអាចធ្វើប្រតិបត្តិការមានប្រសិទ្ធភាព ធ្វើការទូទាត់ថ្លៃទំនិញ និងសេវាកម្ម និងធ្វើឱ្យម៉ាស៊ីនអេធីអឹមមានប្រសិទ្ធភាព។

២. "កិច្ចព្រមព្រៀង" សំដៅលើកិច្ចព្រមព្រៀងនេះដែលអាចមានការកែប្រែពីពេលមួយទៅពេលមួយ។

៣. "ពាក្យស្នើសុំ" សំដៅលើ ទម្រង់ស្នើសុំរបស់ធនាគារសម្រាប់ប្រើប្រាស់ប័ណ្ណដែលត្រូវចេញផ្សាយបន្ទាប់ពី ខ និង លក្ខខណ្ឌទាំងនេះ។

៤. "អេធីអឹម" សំដៅលើ ម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ ឬប័ណ្ណដែលធ្វើប្រតិបត្តិការដោយម៉ាស៊ីនដែល ទទួលស្គាល់ដោយ ប័ណ្ណ ដោយក្នុងនោះរួមមានម៉ាស៊ីនដែលជាកម្មសិទ្ធិរបស់ធនាគារ ឬបណ្តាញ Visa International /Mastercard នៅទូទាំងពិភពលោក/Easycash/បណ្តាញអេធីអឹមនៃប្រព័ន្ធ CSS។ "ដៃគូអាជីវកម្មដែលទទួលបានសិទ្ធិអនុញ្ញាត" សំដៅលើអ្នកលក់រាយ ឬបុគ្គលផ្សេងក្រុមហ៊ុន ឬសាជីវកម្មដែលស្របតាមកិច្ចព្រមព្រៀងដៃគូអាជីវកម្មដែលយល់ព្រមទទួលយក ឬអាចឱ្យហាងរបស់ខ្លួនទទួលយកប័ណ្ណនៅពេលបង្ហាញត្រឹមត្រូវ។

៥. "ធនាគារ" សំដៅលើធនាគារកម្ពុជាសាធារណៈ។

៦. "ប័ណ្ណ" សំដៅលើប័ណ្ណ Campu Bank Visa/Mastercard/ប័ណ្ណអេធីអឹម Proprietary ដែលចេញដោយធនាគារ ស្របតាមកិច្ចព្រមព្រៀងនេះ និងការជំនួស ឬការបន្ត។

៧. "សមាជិកប័ណ្ណ" សំដៅលើបុគ្គលដែលកាន់កាប់ប័ណ្ណដែលភ្ជាប់ដោយផ្ទាល់ទៅគណនីរបស់គាត់/នាង។

៨. "ប្រតិបត្តិការប័ណ្ណ" សំដៅលើប្រតិបត្តិការដែលធ្វើឱ្យមានប្រសិទ្ធភាពតាមរយៈការប្រើប័ណ្ណ។

៩. "សមតុល្យបច្ចុប្បន្ន" សំដៅលើសមតុល្យដែលអាចប្រើប្រាស់បានក្នុងគណនី បន្ទាប់ពីកាត់កងការថ្លៃទិញទំនិញ និង/ឬ សេវាកម្មដែលបានទូទាត់ដោយសមាជិកប័ណ្ណ។

១០. "ប្រតិបត្តិការអេឡិចត្រូនិច" សំដៅលើប្រតិបត្តិការដែលធ្វើឱ្យមានប្រសិទ្ធភាពតាមរយៈការប្រើប្រាស់ប័ណ្ណដើម្បីធ្វើឱ្យ ការផ្ទេរប្រាក់អេឡិចត្រូនិចមានប្រសិទ្ធភាពនៅតាមម៉ាស៊ីនអេធីអឹម ឬប័ណ្ណផ្សេងដែលដំណើរការដោយម៉ាស៊ីន ឬ ឧបករណ៍ដែលទទួលស្គាល់ប័ណ្ណ។

១១. "PIN" សំដៅលើលេខកំណត់អត្តសញ្ញាណបុគ្គលដែលកំណត់ដោយសមាជិកប័ណ្ណដើម្បីដំណើរការការប្រើប្រាស់ប័ ណ្ណ ហើយក្រោយមកនឹងអាចឱ្យសមាជិកប័ណ្ណធ្វើឱ្យមានប្រសិទ្ធភាពដល់ប្រតិបត្តិការតាមរយៈម៉ាស៊ីនអេធីអឹម និង/ឬ ធ្វើឱ្យមានប្រសិទ្ធភាពដល់ការទិញណាមួយជាមួយដៃគូអាជីវកម្មដែលទទួលបានសិទ្ធិអនុញ្ញាត។

១២. "វិក្កយបត្របញ្ជាក់ប្រតិបត្តិការ" សំដៅទៅលើបង្កាន់ដៃទូទាត់ដែលពាក់ព័ន្ធ ឬក្រដាសដែលផ្តត់ផ្តង់ដោយធនាគារជូន ដៃគូអាជីវកម្មដែលទទួលបានសិទ្ធិអនុញ្ញាតក្នុងគោលបំណងកត់ត្រាទុក បញ្ជាក់ និងធ្វើជាភស្តុតាងបញ្ជាក់ការទិញ ឬសេវាកម្មដែលបានទូទាត់ដោយសមាជិកប័ណ្ណតាមរយៈការប្រើប្រាស់ប័ណ្ណ និងកាត់ប្រាក់ពីគណនី។

១៣. "ថ្ងៃធ្វើការ" សំដៅលើថ្ងៃដែលធនាគារបើកអាជីវកម្ម។

១៤. "ប្រតិបត្តិការសរុប" សំដៅលើចំនួនទឹកប្រាក់សរុបនៃប្រតិបត្តិការប័ណ្ណរបស់សមាជិកប័ណ្ណ និង ប័ណ្ណអេធីអឹម។ ចំពោះតែគោលបំណងកំណត់ប្រតិបត្តិការសរុបការប្រើប្រាស់ប័ណ្ណជាប័ណ្ណអេធីអឹមត្រូវចាត់ទុកជាប្រតិបត្តិការប័ណ្ណ។

១៥. "សមតុល្យសរុបរក្សាទុកក្នុងគណនី" សំដៅលើចំនួនទឹកប្រាក់សរុបក្នុងគណនីរបស់សមាជិប័ណ្ណដែលរក្សាទុកដោយ ធនាគារសល់ពីប្រតិបត្តិការនៃប័ណ្ណ និង

១៦. ពាក្យពេចន៍រួមមានឯកវចនៈ និងពហុវចនៈ ឬទាំងពីរ។

១៧. ពាក្យពេចន៍សំដៅលើបុល្លិង្គ ឥត្ថីលិង្គ និងនបុំសកលិង្គ។

១៨. ប្រការយោងសំដៅលើប្រការនៃកិច្ចព្រមព្រៀងនេះ។

១៩. ចំណងជើងនៃប្រការនានាគ្រាន់តែសម្រាប់ការយោងប៉ុណ្ណោះ ហើយមិនត្រូវលើកយកមកពិនិត្យក្នុងការបកស្រាយកិច្ចព្រមព្រៀងនេះទេ។

២. ការទទួលស្គាល់ និងការប្រើប្រាស់ប័ណ្ណ

២.១ ការប្រើប្រាស់ប័ណ្ណត្រូវបានរឹតត្បិតចំពោះបុគ្គលដែលទទួលបានប័ណ្ណ ("សមាជិកប័ណ្ណ") ដែលត្រូវចុះហត្ថលេខាភ្លាមៗបន្ទាប់ពីការទទួល និងការប្រគល់ត្រឡប់មកនូវការបញ្ជាក់ថាបានទទួលប័ណ្ណធនាគារ។ ហត្ថលេខា និង/ឬការប្រើប្រាស់ប័ណ្ណនេះត្រូវបង្កើតបានជាភស្តុតាងដាក់បន្ទុក និងដាច់ស្រេចដែលសមាជិកប័ណ្ណត្រូវអនុវត្តតាមកិច្ចព្រមព្រៀងនេះ។

២.២ ប្រសិនបើ ប័ណ្ណ ត្រូវបានចេញ ដោយមានពាក្យសរសេរ ថាសម្រាប់ បុគ្គលពិការ និង/ឬ ពិការភ្នែក ឬខ្សោយភ្នែក សមាជិកប័ណ្ណទទួលស្គាល់ថា ម៉ាស៊ីនអេធីអឹម និងសេវាប្រតិបត្តិការធនាគារមួយចំនួនមិនត្រូវរៀបចំសម្រាប់សមាជិកប័ណ្ណដែលពិការ និង/ឬពិការភ្នែក ឬខ្សោយភ្នែកប្រើប្រាស់ឡើយ។ សមាជិកប័ណ្ណយល់ព្រមទទួលយកហានិភ័យលើការប្រើប្រាស់សេវាទាំងនេះ ហើយមិនឱ្យធនាគារទទួលខុសត្រូវចំពោះការខាតបង់ ការខូចខាត ថ្លៃដើម និង/ឬការចំណាយដែលសមាជិកប័ណ្ណបានរ៉ាប់រងដោយសារការប្រើប្រាស់ម៉ាស៊ីនអេធីអឹម និង/ឬសេវាធនាគារអេឡិចត្រូនិចដូចបានរៀបរាប់ខាងលើ។

២.៣ ធនាគារនឹងផ្តល់លេខ PIN សម្រាប់ប័ណ្ណជូនសមាជិកប័ណ្ណ ដើម្បីធ្វើឱ្យមានប្រសិទ្ធភាពលើ ប្រតិបត្តិការ តាមម៉ាស៊ីន អេធីអឹមនិង/ឬ ធ្វើឱ្យមានប្រសិទ្ធភាពលើប្រតិបត្តិការទិញទំនិញ នៅតាមដៃគូអាជីវកម្មដែលទទួលបានសិទ្ធិអនុញ្ញាត។ សមាជិកប័ណ្ណធានាអះអាងថាមិនបញ្ចេញលេខ PIN ទៅបុគ្គលណាមួយផ្សេងទៀត ហើយទទួលខុសត្រូវចំពោះធនាគារចំពោះការកាត់ប្រាក់ដែលបានកត់ត្រាក្នុងគណនីរបស់ខ្លួនដែលមាននៅធនាគារ ដោយសារការធ្វើប្រតិបត្តិការដែលគ្មានសិទ្ធិអនុញ្ញាត។

២.៤ ក្នុងករណីសមាជិកប័ណ្ណមិនចង់អនុវត្តតាមខ និងលក្ខខណ្ឌទាំងនេះ សមាជិកប័ណ្ណត្រូវប្រគល់ប័ណ្ណដែលកាត់ជាពីរមកធនាគារវិញភ្លាមៗ ឬជូនដំណឹងជាលាយលក្ខណ៍អក្សរ និងបំផ្លាញ/លុបឆីពដែលមាននៅលើប័ណ្ណចោល។ សមាជិកប័ណ្ណត្រូវចាត់ទុកថាទទួលស្គាល់ និងអនុវត្តតាមខ និងលក្ខខណ្ឌទាំងនេះ ក្នុងករណីធនាគារមិនបានទទួលប័ណ្ណដែលកាត់ជាពីរ ឬការជូនដំណឹងជាលាយលក្ខណ៍អក្សរណាមួយ។

២.៥ ប័ណ្ណដែលរួមបញ្ចូលទាំងរូបវន្ត ឌីជីថល ឬរូបភាពជាក់ស្តែង នឹងអាចឱ្យសមាជិកប័ណ្ណធ្វើប្រតិបត្តិការដូចខាងក្រោម៖

- ហត្ថលេខាផ្អែកលើប្រតិបត្តិការនៅតាមដៃគូអាជីវកម្មដែលទទួលបានសិទ្ធិអនុញ្ញាត ត្រូវចាត់ទុកជាភស្តុតាងដាច់ស្រេច ហើយចំនួនទឹកប្រាក់ដែលបានកត់ត្រាត្រូវទូទាត់ទៀងទាត់នៅពេលដែលធនាគារទទួលបាន វិក្កយបត្របញ្ជាក់ប្រតិបត្តិការ ឬឯកសារជាលាយលក្ខណ៍អក្សរដែលមានហត្ថលេខារបស់សមាជិកប័ណ្ណ។
- លេខ PIN ផ្អែកលើប្រតិបត្តិការនៅតាមដៃគូអាជីវកម្មដែលទទួលបានសិទ្ធិអនុញ្ញាត។

- ប្រតិបត្តិការតាមអនឡាញតាមរយៈកុំព្យូទ័រ ឬឧបករណ៍ចល័ត ឬកម្មវិធីដែលតភ្ជាប់កុំព្យូទ័រដែលអាចតភ្ជាប់បានមិនថាតម្រូវឱ្យមាន ឬគ្មានលេខសម្ងាត់របស់សមាជិកប័ណ្ណក៏ដោយ។

  ក- ក្នុងករណីប័ណ្ណត្រូវបានចេញជូនដើម្បីទិញទំនិញ និង/ឬសេវាកម្មតាមរយៈបណ្តាញ ឬគេហទំព័រលើអ៊ីនធើណិត (រាប់បញ្ចូលតាមរយៈកុំព្យូទ័រ ឬឧបករណ៍ចល័ត) សមាជិកប័ណ្ណត្រូវទទួលខុសត្រូវតែម្នាក់ឯងចំពោះសុវត្ថិភាពនៃការប្រើប្រាស់គ្រប់ពេលវេលា។ សមាជិកប័ណ្ណយល់ព្រមថា ការបញ្ចូលព័ត៌មានប័ណ្ណក្នុងបណ្តាញអ៊ីនធើណិតមានភស្តុតាងគ្រប់គ្រាន់ សម្រាប់ការបញ្ជាប្រើប្រាស់ប័ណ្ណ។

  ខ- ធនាគារមិនទទួលខុសត្រូវ ចំពោះការផ្ទៀងផ្ទាត់អត្តសញ្ញាណ ឬការផ្តល់សិទ្ធិអនុញ្ញាតរបស់បុគ្គល ដែលបញ្ចូលព័ត៌មានប័ណ្ណរបស់សមាជិកប័ណ្ណ។ ធនាគារមិនទទួលខុសត្រូវចំពោះសកម្មភាពណាមួយលើការប្រើប្រាស់ប័ណ្ណរបស់សមាជិកប័ណ្ណ ដោយមិនគិតថា តើបុគ្គលដែលបានបញ្ចូលព័ត៌មានប័ណ្ណនោះ ទទួលបានសិទ្ធិអនុញ្ញាតឱ្យធ្វើដូច្នេះឡើយ ហើយមិនរាប់បញ្ចូលទាំងកាលៈទេសៈនៅពេលដែលប្រតិបត្តិការមានប្រសិទ្ធភាពឡើយ។

  គ- តាមការកំណត់ភាពសមស្របរបស់ធនាគារ ធនាគារអាចជ្រើសរើសមិនយកការធ្វើប្រតិបត្តិការ តាមអ៊ីនធើណិត ប្រសិនបើធនាគារមានហេតុផលណាមួយសង្ស័យថាការផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ខ្លួន ឬប្រសិនបើធនាគារយល់ឃើញថាប្រតិបត្តិការខុសច្បាប់ ឬមិនត្រឹមត្រូវក្នុងការធ្វើដូច្នេះ ឬដោយសារហេតុផលណាមួយផ្សេងទៀត។

- ប្រតិបត្តិការតាមបច្ចេកវិទ្យា Contactless គឺមិនចាំបាច់ឆូតប័ណ្ណលើម៉ាស៊ីនអានតាមបច្ចេកវិទ្យា Contactless ម៉ាស៊ីនឆូតកាត ឬឧបករណ៍ម៉ាស៊ីនឆូតកាត ឬការដាក់ប័ណ្ណនៅជិតឧបករណ៍ទាំងនោះ។ ក្នុងករណីមិនមានការជូនដំណឹងទេ ប្រតិបត្តិការតាមបច្ចេកវិទ្យា Contactless មិនតម្រូវឱ្យប្រើប្រាស់៖
  ក. ហត្ថលេខារបស់សមាជិកប័ណ្ណលើបង្កាន់ដៃទិញទំនិញ ម៉ាស៊ីន ឬឧបករណ៍ម៉ាស៊ីនឆូតកាត
  ខ. មីក្រូឆីបនៅលើប័ណ្ណ ប្រសិនបើមាន ត្រូវឆូតដោយឧបករណ៍ទាំងនេះ
  គ. PIN ដែលអនុញ្ញាតឱ្យធ្វើប្រតិបត្តិការនេះ

២.៦ តបទៅតាមការដែលសមាជិកប័ណ្ណគោរព និងអនុវត្តតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះ ធនាគារត្រូវទទួលយកវិក្កយបត្របញ្ជាក់ការធ្វើប្រតិបត្តិការពីដៃគូអាជីវកម្មទទួលបានសិទ្ធិអនុញ្ញាត និង/ឬគ្រឹះស្ថានជាសមាជិក Visa International /Mastercard នៅទូទាំងពិភពលោក/Easycash/ប្រព័ន្ធ CSS ដែលបានទូទាត់ដោយសមាជិកប័ណ្ណ រួចហើយទូទាត់ពីគណនី។

បើទោះបីជាមានបទប្បញ្ញត្តិដូចមានចែងក្នុងប្រការ ២.៥ (ក) ខាងលើ ហត្ថលេខាមិនមែនជាលក្ខខណ្ឌដាក់បន្ទុកការទទួលខុសត្រូវរបស់សមាជិកប័ណ្ណពាក់ព័ន្ធទៅនឹងទំនិញ និងសេវាកម្មដែលបានផ្តត់ផ្តង់ ប្រសិនបើធនាគារយល់ឃើញថាភស្តុតាងមានគ្រប់គ្រាន់បង្ហាញថាព័ត៌មានមិនគ្រប់គ្រាន់គឺបណ្តាលមកពីលក្ខណៈនៃការធ្វើប្រតិបត្តិការ ឬដោយសារកំហុសឆ្គងដោយភាគីសមាជិកប័ណ្ណ និង/ឬដៃគូអាជីវកម្មដែលទទួលបានសិទ្ធិអនុញ្ញាត និង/ឬធនាគារជាសមាជិក Visa International /Mastercard នៅទូទាំងពិភពលោក/Easycash/ប្រព័ន្ធ CSS។

២.៧ សមាជិកប័ណ្ណត្រូវអនុវត្តតាមលក្ខខណ្ឌតម្រូវ សារាចរណែនាំ បទបញ្ជា និងសេចក្តីណែនាំអំពីការប្រើប្រាស់ប័ណ្ណដែលចេញដោយធនាគារពីពេលមួយទៅពេលមួយពាក់ព័ន្ធទៅនឹងសេវាកម្មទាំងអស់ដែលផ្តល់ជូនសមាជិកប័ណ្ណ។

២.៨ សមាជិកប័ណ្ណមិនត្រូវប្រើប្រាស់ប័ណ្ណដើម្បីបម្រើសកម្មភាពខុសច្បាប់នានា មានដូចជា ការភ្នាល់ល្បែងខុសច្បាប់តាមអនឡាញ។ ក្នុងករណីមានការរកឃើញថា សមាជិកប័ណ្ណប្រើប្រាស់ ឬបានប្រើប្រាស់ ប័ណ្ណដើម្បីបម្រើសកម្មភាពខុសច្បាប់ ដូចមានចែង ក្នុងបទប្បញ្ញត្តិ នៃកិច្ចព្រមព្រៀងនេះ ធនាគារមានសិទ្ធិបញ្ចប់ ការប្រើប្រាស់ប័ណ្ណ របស់ សមាជិកប័ណ្ណភ្លាមៗ។

៣. ដំណើរការនៃប័ណ្ណ

៣.១ ប័ណ្ណត្រូវរក្សាជាទ្រព្យសម្បត្តិរបស់ធនាគារគ្រប់ពេលវេលា។ ប័ណ្ណនេះត្រូវប្រើប្រាស់ផ្តាច់មុខដោយសមាជិកប័ណ្ណ។ សមាជិកប័ណ្ណមិនត្រូវផ្ទេរ ឬផ្ទេរផ្នែកណាមួយនៃការត្រួតពិនិត្យ ឬការកាន់កាប់ប័ណ្ណ ការប្រើប្រាស់ ឬគោលបំណងដែលមិនទទួលបានការអនុញ្ញាតពីធនាគារឡើយ។ សមាជិកប័ណ្ណមិនត្រូវដាក់បញ្ចាំប័ណ្ណនេះសម្រាប់គោលបំណងណាមួយឡើយ។

៣.២ សមាជិកប័ណ្ណត្រូវអនុវត្តប្រកបដោយភាពប្រុងប្រយ័ត្នដើម្បីបង្ការការបាត់បង់ ឬចោរលួចប័ណ្ណនេះ។ ក្នុងករណីមានការបាត់បង់ ឬចោរលួចប័ណ្ណនេះ និង/ឬការបញ្ចេញព័ត៌មាន PIN ទៅបុគ្គលណាមួយដែលមិនទទួលបានសិទ្ធិអនុញ្ញាត សមាជិកប័ណ្ណត្រូវជូនដំណឹងភ្លាមៗមកធនាគារ បន្ទាប់ពីមានការបាត់បង់ ឬចោរលួចប័ណ្ណ (ប្រសិនបើការបាត់បង់ ឬចោរលួចកើតឡើងនៅប្រទេសកម្ពុជា) ឬសមាជិកក្រុមហ៊ុន Visa International /Mastercard នៅទូទាំងពិភពលោក (ប្រសិនបើការបាត់បង់ ឬចោរលួចកើតឡើងនៅក្រៅប្រទេស) តាមរយៈទូរស័ព្ទ ហ្វាក ឬអ៊ីម៉ែល ហើយបញ្ហាដដែលនេះជាលាយលក្ខណ៍អក្សរមកធនាគារ ដោយភ្ជាប់មកជាមួយនូវពាក្យបណ្តឹងទៅប៉ូលីស។

៣.៣ សមាជិកប័ណ្ណព្រមព្រៀងដោយឥតប្រកែកតវ៉ា និងឥតលក្ខខណ្ឌថា ធនាគារអាច (ប៉ុន្តែមិនតម្រូវ) កត់ត្រាការបញ្ជាតាមទូរស័ព្ទដូចមានរៀបរាប់ខាងលើជាលាយលក្ខណ៍អក្សរ និង/ឬថតសំឡេង និង/ឬតាមវិធីផ្សេងៗទៀត ហើយការកត់ត្រាការបញ្ជាណាមួយត្រូវដាច់ស្រេច និងភ្ជាប់កាតព្វកិច្ចចំពោះសមាជិក ប័ណ្ណ។ សមាជិកប័ណ្ណព្រមព្រៀងយ៉ាងច្បាស់លាស់ថា ការបញ្ជាតាមទូរស័ព្ទអាចត្រូវបានកត់ត្រា និងទទួលស្គាល់ថា ការកត់ត្រាណាមួយ និង/ឬការកត់ត្រាទាំងអស់ដែលធនាគាររក្សាទុកត្រូវដាច់ស្រេច និងភ្ជាប់កាតព្វកិច្ចចំពោះគោលបំណងទាំងអស់។ សមាជិកប័ណ្ណព្រមព្រៀងបន្ថែមទៀតថា ធនាគារមិនមានកាតព្វកិច្ចណាមួយក្នុងការផ្ទៀងផ្ទាត់អត្តសញ្ញាណ ឬការផ្តល់សិទ្ធិអនុញ្ញាតរបស់បុគ្គលដែលផ្តល់ការបញ្ជាតាមទូរស័ព្ទជាឈ្មោះសមាជិកប័ណ្ណ ហើយធនាគារមានសិទ្ធិអនុវត្តតាមការបញ្ជានេះ និងមិនត្រូវទទួលខុសត្រូវចំពោះការបញ្ជាដែលមានភាពសុច្ចរិតទៀងត្រង់តាមទូរសព្ទ័ ដែលបានផ្តល់ជូនតាម រយៈបុគ្គលនេះ ដោយមិនគិតពីកាលៈទេសៈដែលការបញ្ជានេះមានប្រសិទ្ធភាព។ ស្របតាមប្រការខាងលើ សមាជិកប័ណ្ណទទួលស្គាល់ថា តបទៅតាមការដែលធនាគារអនុវត្តតាមការបញ្ជាតាមទូរស័ព្ទខាងលើ ឬតាមការព្រមព្រៀងរបស់សមាជិកប័ណ្ណឱ្យធនាគារថតសំឡេងការហៅតាមទូរស័ព្ទផ្នែកណាមួយ ឬផ្នែកទាំងអស់របស់សមាជិកប័ណ្ណជាមួយធនាគារ ដើម្បីអាចឱធនាគាររក្សាទុកការថតសំឡេង ទាំងអស់ ឬការបញ្ជា ណាមួយដែល ផ្តល់ដោយ សមាជិកប័ណ្ណ ឬ ជាឈ្មោះសមាជិកប័ណ្ណ មកធនាគារ សមាជិក

ប័ណ្ណយល់ព្រមសងសំណងជូនធនាគារ និងរក្សាសងសំណងជូនធនាគារគ្រប់ពេលចំពោះការខាតបង់ សិទ្ធិលើបំណុល សំណុំរឿងបណ្តឹង ការទាមទារ ការខូចខាត ថ្លៃដើម និងការចំណាយដែលបានរ៉ាប់រង ឬទំនុកបម្រុងដោយធនាគារ មិនថាកើតឡើងដោយសារ ឬពាក់ព័ន្ធនឹងការបញ្ជាខាងលើទេ។

៣.៤ ក្នុងករណីមានការបាត់បង់/ចោរលួច ដូចបានលើកឡើងក្នុងប្រការ ៣.២ ខាងលើ និងប្រសិនបើក្រោយពេលការបាត់បង់/ចោរលួច ប័ណ្ណត្រូវបានប្រើប្រាស់ដោយបុគ្គលដែលមិនទទួលបានសិទ្ធិអនុញ្ញាត សមាជិកប័ណ្ណត្រូវទទួលខុសត្រូវចំពោះធនាគារចំពោះកម្រៃកើតពីប្រតិបត្តិការ ដែលធ្វើឡើងដោយមិនទទួលបានសិទ្ធិអនុញ្ញាត ក្នុងនោះរួមមានបន្ទុកហិរញ្ញវត្ថុ ដែលបានទូទាត់ថ្លៃទំនិញ ឬសេវាកម្មដែលបានផ្គត់ផ្គងដោយដៃគូអាជីវកម្ម ដែលធ្វើឱ្យមានប្រសិទ្ធភាពតាមរយៈការប្រើប្រាស់ប័ណ្ណដោយបុគ្គលដែលមិនទទួលបានសិទ្ធិអនុញ្ញាត រហូតដល់កាលបរិច្ឆេទដែលធនាគារទទួលបានការជូនដំណឹងជាលាយលក្ខណ៍អក្សរពីសមាជិកប័ណ្ណដូចបានកំណត់យ៉ាងច្បាស់ក្នុងប្រការ ៣.២ ខាងលើ។ សមាជិកប័ណ្ណត្រូវទទួលខុសត្រូវចំពោះរាល់បន្ទុកដែលកើតឡើងដោយមិនមានការអនុញ្ញាត ក្នុងករណីសមាជិកប័ណ្ណប្រព្រឹត្តការក្លែងបន្លំ មានភាពយឺតយ៉ាវក្នុងការជូនដំណឹងភ្លាមៗមកធនាគារ បន្ទាប់ពីមានការបាត់/ចោរលួច ឬការប្រើប្រាស់ប័ណ្ណដោយមិនទទួលបានការអនុញ្ញាត ការផ្តល់លេខ PIN ទៅបុគ្គលផ្សេងទៀតដោយស្ម័គ្រចិត្ត សរសេរលេខ PIN នៅលើប័ណ្ណ ឬនៅត្រង់ណាមួយនៅលើប័ណ្ណ និងបាត់ជាមួយប័ណ្ណ ឬទុកចោលប័ណ្ណ ឬរបស់ដែលមានប័ណ្ណ មិនបានយកចិត្តទុកដាក់ និង/ឬ អនុញ្ញាតឱ្យបុគ្គលផ្សេងទៀតប្រើប្រាស់ប័ណ្ណដោយស្ម័គ្រចិត្ត។

ប្រសិនបើការតាមដានបង្ហាញថា សមាជិកប័ណ្ណ មានជាប់ពាក់ព័ន្ធក្នុងការទូទាត់សោហ៊ុយដែលកើតឡើងដោយមិនមានការអនុញ្ញាត សមាជិកប័ណ្ណ ត្រូវទទួលខុសត្រូវចំពោះសោហ៊ុយដែលកើតឡើងដោយមិនមានការអនុញ្ញាតដែលបានទូទាត់ ដោយក្នុងនោះរួមមានបន្ទុកហិរញ្ញវត្ថុ មិនថាកើតឡើងមុន ឬក្រោយពេលធនាគារទទួលបានការបញ្ជាក់ជាលាយលក្ខណ៍អក្សរឡើយ។

៣.៥ រាល់ការប្តឹងទាមទារពីការបាត់ ឬចោរលួចប័ណ្ណ ឬប្រតិបត្តិការមានវិវាទដែលបានធ្វើឡើងលើប័ណ្ណ ធនាគារនឹងធ្វើការស៊ើបអង្កេត បន្ទាប់ពីទទួលបានព័ត៌មានពាក់ព័ន្ធនានា ស្របតាមការសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជា និងនីតិវិធីស៊ើបអង្កេតផ្ទៃក្នុងរបស់ធនាគារ។ ក្នុងករណីធនាគាររកឃើញថា មានការព្យាយាមក្លែងបន្លំការប្តឹងទាមទារលើប្រតិបត្តិការមានវិវាទ ធនាគាររក្សាសិទ្ធិ ដាក់ពាក្យបណ្តឹងទៅ មន្ត្រីប៉ូលីសអំពី ការក្លែងបន្លំការ ប្តឹងទាមទារ និង/ឬ បញ្ចប់ការប្រើប្រាស់ប័ណ្ណនេះតាមភាពជាក់ស្តែង ហើយសមាជិកប័ណ្ណទទួលខុសត្រូវចំពោះចំនួនទឹកប្រាក់នៃប្រតិបត្តិការដែលមានវិវាទ និងថ្លៃដើម ព្រមទាំងការចំណាយដែលធនាគារបានរ៉ាប់រង។

៣.៦ ធនាគារតបតាមសំណើសុំ របស់សមាជិកប័ណ្ណអាចកំណត់កម្រៃ និងសោហ៊ុយដូចខាងក្រោម សម្រាប់ការជំនួសប័ណ្ណនីមួយៗ ប៉ុន្តែមិនមែនច្បាប់កំណត់៖

		ប័ណ្ណអេធីអឹម Proprietary ធនាគារកម្ពុ		**ប័ណ្ណឥណពន្ធ Visa/Mastercard Lifestyle ធនាគារកម្ពុ**	
ល.រ	**បរិយាយ**	**ដុល្លារអាមេរិក**	**ខ្មែររៀល**	**ដុល្លារអាមេរិក**	**ខ្មែររៀល**
១	**ពាក្យស្នើសុំថ្មី**				
	កម្រៃប្រចាំឆ្នាំ	៦ ដុល្លារអាមេរិក	២៤.០០០ រៀល	១២ ដុល្លារអាមេរិក	៤៨.០០០ រៀល
	សម្គាល់៖ កម្រៃប្រចាំឆ្នាំដំបូងត្រូវទូទាត់ជាមុន រីឯកម្រៃប្រឆ្នាំទី ២ នឹងត្រូវកាត់កងដោយស្វ័យប្រវត្តិពីគណនីប្រាក់បញ្ញើរបស់ អតិថិជន ផ្អែកលើចំនួនសមាមាត្រប្រចាំខែ				
២	ការប្តូរប័ណ្ណដោយ				
	• បាត់ ឬចោរលួចប័ណ្ណ	៦ ដុល្លារអាមេរិក	២៤.០០០ រៀល	១០ ដុល្លារអាមេរិក	៤០.០០០ រៀល
	• ភ្លេច ឬលេខ PIN ត្រូវបានគេស្គាល់	៦ ដុល្លារអាមេរិក	២៤.០០០ រៀល	១០ ដុល្លារអាមេរិក	៤០.០០០ រៀល
	• ខូចដោយសារ សឹក និងរហែក	៦ ដុល្លារអាមេរិក	២៤.០០០ រៀល	១០ ដុល្លារអាមេរិក	៤០.០០០ រៀល

សម្គាល់៖ កម្រៃមិនត្រូវបានបង្វិលត្រឡប់វិញឡើយ

ដោយហេតុថា ប័ណ្ណមិនត្រូវបានជំនួស ក្នុងករណីមានរបាយការណ៍អំពីការបាត់ ឬចោរលួចប័ណ្ណចាប់ពីបួនលើកឡើងទៅ។ ប័ណ្ណជំនួសត្រូវអនុលោមតាមខ និងលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះ បើទោះបីជាវាជាប័ណ្ណដើមក៏ ដោយ។

៣.៧ សមាជិកប័ណ្ណត្រូវប្រគល់ប័ណ្ណដែលកាត់ជាពីរមកធនាគារ ឬលុប/បំផ្លាញនីបក្នុងប័ណ្ណភ្លាម។ បន្ទាប់ពីកាលបរិច្ឆេទផុតកំណត់ ឬ តាមការ ទាមទារ របស់ធនាគារ បន្ទាប់ការលុបចោល ការដកហូត ឬការ ព្យួររបស់ធនាគារ ឬ បន្ទាប់ពី រកឃើញប័ណ្ណ បន្ទាប់ជូនដំណឹងអំពីការបាត់ ហើយមិនមានសិទ្ធិបន្តប្រើប្រាស់ប័ណ្ណនេះ។

៤. គណនីប័ណ្ណ

៤.១ រាល់ការទូទាត់ថ្លៃទំនិញ និង/ឬសេវាកម្មដែលមានប្រសិទ្ធភាពតាមរយៈការប្រើប្រាស់ប័ណ្ណ និងកម្រៃប្រចាំឆ្នាំ សោហ៊ុយគ្រប់គ្រង និងសោហ៊ុយបន្ថែម និងការដកប្រាក់តាមម៉ាស៊ីនអេធីអឹមត្រូវកាត់កងទៅគណនីតាមចំនួនកំណត់ក្នុងវិក្កយបត្រទាំងក្នុងស្រុក និងក្រៅប្រទេស និងមាននៅក្នុងរបាយការណ៍។

៥. សមតុល្យអប្បបរមា

៥.១. ធនាគារអាចកំណត់សមតុល្យអប្បបរមា ដែលត្រូវរក្សាទុកក្នុងគណនីពាក់ព័ន្ធទៅនឹងការប្រើប្រាស់ប័ណ្ណ និងអាចកែប្រែសមតុល្យអប្បបរមាពីពេលមួយទៅពេលមួយ ដោយមិនមានការជូនដំណឹង បើទោះបីជាមិនតម្រូវសម្រាប់ប័ណ្ណអេធីអឹម Proprietary ថ្មី។

៥.២ ក្នុងករណីសមតុល្យអប្បបរមាណាមួយអាចត្រូវបានស្នើសុំ តាមឆន្ទានុសិទ្ធិរបស់ខ្លួន ធនាគារអាចអនុម័តប្រតិបត្តិការប័ណ្ណដែលបានស្នើសុំ និង/ឬប្រតិបត្តិការប័ណ្ណអេឡិចត្រូនិច និងអនុញ្ញាតឱ្យមានសមតុល្យអប្បបរមាលើសកម្រិត បើទោះបីជាមិនមានការស្នើសុំពីសមាជិកប័ណ្ណ ដោយហេតុថា សមាជិកប័ណ្ណត្រូវទូទាត់ចំនួនទឹកប្រាក់លើសពីសមតុល្យអប្បបរមាដែលបានកំណត់។

៥.៣ តាមឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងករណីធនាគារអនុញ្ញាតឱ្យដកប្រាក់លើសកម្រិតកំណត់ក្នុងគណនីផ្អែកលើហេតុផលណាមួយ សមាជិកប័ណ្ណត្រូវទូទាត់ចំនួនទឹកប្រាក់ដែលបានដកលើសកម្រិតកំណត់ បូករួមទាំងការប្រាក់នៃចំនួនទឹកប្រាក់ ដែលបានដកលើសកម្រិតតាមការកំណត់របស់ធនាគារពីពេលមួយទៅពេល មួយ។

៥.៤ ក្នុងការគណនាថាតើសមតុល្យអប្បបរមាប៉ុន្មានត្រូវរក្សាទុក និងមិនលើសកម្រិតកំណត់ ធនាគារអាច ពិនិត្យចំនួនទឹកប្រាក់នៃប្រតិបត្តិការប័ណ្ណណាមួយ និង/ឬប្រតិបត្តិការប័ណ្ណអេឡិចត្រូនិចដែលមិនទាន់កាត់ចូលគណនី និងសិទ្ធិអនុញ្ញាតដែលផ្តល់ដោយធនាគារទៅភាគីទីបីពាក់ព័ន្ធទៅនឹងប្រតិបត្តិការប័ណ្ណ និង/ឬប្រតិបត្តិការប័ណ្ណអេឡិចត្រូនិចនីមួយៗ។

៥.៥ សមាជិកប័ណ្ណត្រូវរក្សាសមតុល្យអប្បបរមាក្នុងគណនីគ្រប់ពេលតាមការកំណត់របស់ធនាគារ។

៦. ឆន្ទានុសិទ្ធិរបស់ធនាគារ

៦.១ ធនាគារ មានឆន្ទានុសិទ្ធិគ្រប់ពេលក្នុងការបដិសេធ មិនអនុម័តប្រតិបត្តិការប័ណ្ណដែលបានស្នើសុំ ដោយមិនមានការជូនដំណឹង និងផ្តល់មូលហេតុ បើទោះបីជា សមតុល្យដែលអាចប្រើប្រាស់បានបច្ចុប្បន្នអាចធ្វើប្រតិបត្តិការបាន។

៧. PIN និងការប្រើប្រាស់ម៉ាស៊ីនអេធីអឹម/ធ្វើឱ្យប្រតិបត្តិការអេឡិចត្រូនិចមានប្រសិទ្ធភាព

៧.១ សមាជិកប័ណ្ណនឹងតម្រូវមានវត្តមាននៅធនាគារដើម្បីវាយបញ្ចូលលេខ PIN ចំនួន ៦ ខ្ទង់តាមឧបករណ៍ Encrypted PIN PAD (EPP) ឬម៉ាស៊ីនអេធីអឹមដើម្បីដំណើរការប័ណ្ណដែលត្រូវចេញ។

៧.២ ក្នុងករណីសមាជិកប័ណ្ណប្រើប្រាស់ប័ណ្ណនៅតាមម៉ាស៊ីនអេធីអឹម ឬធ្វើឱ្យប្រតិបត្តិការអេឡិចត្រូនិចមានប្រសិទ្ធភាព ត្រូវអនុវត្តតាមលក្ខខណ្ឌបន្ថែមដូចខាងក្រោម៖

(ក) សមាជិកប័ណ្ណមិនត្រូវបង្ហាញលេខ PIN និងត្រូវយកចិត្តទុកដាក់ដើម្បីកុំឱ្យអ្នកដទៃដឹងលេខ PIN។

(ខ) សមាជិកប័ណ្ណត្រូវទទួលខុសត្រូវចំពោះប្រតិបត្តិការ ដែលធ្វើឱ្យមានប្រសិទ្ធភាពតាមរយៈការប្រើប្រាស់នៅតាមម៉ាស៊ីនអេធីអឹម មិនថាសមាជិកប័ណ្ណបាន ឬមិនបានដឹង ឬអនុញ្ញាតឡើយ។

(គ) ចំនួនទឹកប្រាក់នៃការធ្វើប្រតិបត្តិការតាមម៉ាស៊ីនអេធីអឹម/ប្រតិបត្តិការអេឡិចត្រូនិច ក្នុងករណីជារូបិយប័ណ្ណផ្សេងពីរូបិយប័ណ្ណដុល្លារអាមេរិក នឹងត្រូវបង្វែរទៅជាប្រាក់ដុល្លារអាមេរិកក្នុងពេលនោះ ហើយអត្រាប្តូរប្រាក់ត្រូវកំណត់ដោយធនាគារស្របតាមការអនុវត្តជាក់ស្តែង មុនពេលត្រូវកាត់ចូលគណនី និង

(ឃ) តាមឆន្ទានុសិទ្ធិរបស់ខ្លួន ធនាគារមានសិទ្ធិកែប្រែ ផ្អាកដំណើរការ ឬដកហូតការប្រើប្រាស់លេខ PIN នៅពេលណាមួយ ដោយមិនផ្តល់ហេតុផល និងជូនដំណឹងជាមុនទៅសមាជិកប័ណ្ណ។

៨. ការបញ្ឈប់ការប្រើប្រាស់

៨.១ សមាជិកអាចបញ្ឈប់ការប្រើប្រាស់ប័ណ្ណរបស់គាត់/នាងតាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការបញ្ឈប់ការប្រើប្រាស់ និងប្រគល់ប័ណ្ណកាត់ជាពីរមកធនាគារវិញក្រោយមកការប្រើប្រាស់នឹងត្រូវផ្អាក។

៨.២ តាមឆន្ទានុសិទ្ធិដាច់ណាត់របស់ធនាគារ ធនាគារ អាចបញ្ឈប់ ការប្រើប្រាស់នៅពេលណាមួយដោយមិនចាំបាច់ជូនដំណឹង និងផ្តល់ហេតុផល។ ដោយ មិនប៉ះពាល់ដល់ ព័ត៌មាន ទូទៅ ដូចបានរៀបរាប់ ខាងលើ ធនាគារ អាច បញ្ឈប់ ការប្រើប្រាស់ប័ណ្ណនេះ ក្នុងករណីមានព្រឹត្តិការណ៍ណាមួយដូចខាងក្រោមកើតឡើង៖
(ក) ក្ស័យធន អសាធនភាព បាត់បង់ជីវិត ឬអសមត្ថភាពរបស់សមាជិកប័ណ្ណ និង/ឬ
(ខ) សមាជិកប័ណ្ណរំលោភបំពានកិច្ចព្រមព្រៀងនេះ។

៨.៣ ប្រសិនបើ ធនាគារ ឬសមាជិកបញ្ឈប់ការប្រើប្រាស់ប័ណ្ណដោយសារហេតុផលណាមួយ សមាជិកប័ណ្ណត្រូវបង្វិលបណ្ណដែលកាត់ពាក់កណ្តាលមកធនាគារវិញ។

៨.៤ កម្រៃប្រចាំ ឬកម្រៃផ្សេងៗនឹងមិនត្រូវបង្វិលសងវិញឡើយ បន្ទាប់ពីប័ណ្ណត្រូវបានបញ្ឈប់ការប្រើប្រាស់ដោយសារហេតុផលណាមួយ។

៨.៥ បន្ទាប់ពីការបញ្ចប់ការប្រើប្រាស់ប័ណ្ណ ធនាគារនឹងមិនផ្តល់របាយការណ៍ប្រចាំខែដល់សមាជិកប័ណ្ណឡើយ ហើយអត្ថប្រយោជន៍ដែលត្រូវផ្តល់ជូនសមាជិក (ប្រសិនបើមាន) នឹងត្រូវទុកជាមោឃៈ។

៩. ការបដិសេធមិនទទួលខុសត្រូវ

៩.១ ធនាគារមិនទទួលខុសត្រូវចំពោះទំនិញ ឬសេវាកម្មដែលផ្គត់ផ្គង់ដោយដៃគូអាជីវកម្ម ឬគុណភាព ឬប្រសិទ្ធភាពទំនិញ និងសេវាកម្មស្របតាម ឬពាក់ព័ន្ធទៅនឹងប្រតិបត្តិការណាមួយ។ ការទទួលខុសត្រូវរបស់សមាជិកប័ណ្ណចំពោះធនាគារ មិនត្រូវទទួលរងផលប៉ះពាល់ដោយវិវាទណាមួយ ឬការប្តឹងទាមទារតទល់ ឬសិទ្ធិកាត់កងដែលសមាជិកមានដើម្បីតទល់ទៅនឹងដៃគូអាជីវកម្មឡើយ។

៩.២ សមាជិកប័ណ្ណដោះស្រាយការប្តឹងទាមទារ ឬវិវាទដោយផ្ទាល់ជាមួយដៃគូអាជីវកម្មដែលទទួលបានសិទ្ធិអនុញ្ញាត ឬគ្រឹះស្ថានជាសមាជិកបណ្តាញ Visa International / Mastercard នៅទូទាំងពិភពលោក/បណ្តាញ EasyCash/ប្រព័ន្ធ CSS។

៩.៣ ធនាគារមិនទទួលខុសត្រូវក្នុងរូបភាពណាមួយ ប្រសិនបើដៃគូអាជីវកម្មដែលទទួលបានសិទ្ធិអនុញ្ញាតមិនទទួលយក ឬទូទាត់ប័ណ្ណដោយសារហេតុផលណាមួយ។

៩.៤ ធនាគារមិនទទួលខុសត្រូវក្នុងករណីធនាគារមិនអាចបំពេញកាតព្វកិច្ចក្នុងកិច្ចព្រមព្រៀងនេះ ដោយផ្ទាល់ ឬដោយប្រយោល ដោយសារវិវាទឧស្សាហកម្ម ឬសង្គ្រាម ឬប្រធានសក្តិលើសពីការគ្រប់គ្រងរបស់ធនាគារ ឬបុគ្គលិក ឬភ្នាក់ងាររបស់ធនាគារ។

៩.៥ ធនាគារមិនទទួលខុសត្រូវក្នុងរូបភាពណាមួយចំពោះការប៉ះពាល់លើកិត្តិយស ចរិតលក្ខណៈ និង កេរ្តិ៍ឈ្មោះរបស់សមាជិកប័ណ្ណក្នុង និងអំពីការកាន់កាប់ឡើងវិញនៃប័ណ្ណ ឬការស្នើសុំប្រគល់ត្រឡប់។

៩.៦ ធនាគារមិនទទួលខុសត្រូវក្នុងរូបភាពណាមួយចំពោះសមាជិកប័ណ្ណចំពោះផលវិបាក ការបាត់បង់ ការខូចខាត ការប៉ះពាល់លក្ខណៈណាមួយដោយសារ ឬផ្តើមចេញពីការខូចខាត ឬការបាត់បង់ ឬភាព អសមត្ថភាពទាញយកទិន្នន័យ ឬព័ត៌មានដែលអាចរក្សាទុកក្នុងមីក្រូឆីប ឬកាំមេរ៉ាសុវត្ថិភាពដែលបានកើតឡើង។

៩.៧ ដោយមិនប៉ះពាល់ដល់ព័ត៌មានទូទៅនៃបទប្បញ្ញត្តិនៃប្រការ ១៣ ធនាគារមិនទទួលខុសត្រូវក្នុងរូបភាពណាមួយចំពោះសមាជិកប័ណ្ណចំពោះការខាតបង់ ការខូចខាត ថ្លៃដើម ឬការចំណាយលើលក្ខណៈណាមួយដែលផ្តើមចេញពី/ឬពាក់ព័ន្ធទៅនឹងការប្រើប្រាស់ប័ណ្ណ និង/ឬកិច្ចព្រមព្រៀងនេះ។

៩.៨ ដោយមិនប៉ះពាល់ដល់ព័ត៌មានទូទៅនៃបទប្បញ្ញត្តិនៃប្រការ ១៣ ធនាគារមិនទទួលខុសត្រូវក្នុងរូបភាពណាមួយចំពោះសមាជិកប័ណ្ណចំពោះការខាតបង់ ការខូចខាត ឬការប៉ះពាល់លក្ខណៈណាមួយដែលផ្តើមចេញ៖

(ក) ការពន្យាបញ្ចេញទឹកប្រាក់រក្សាទុកក្នុងគណនី

(ខ) ចំនួនទឹកប្រាក់រក្សាទុកណាមួយក្នុងគណនី បន្ទាប់ពីទទួលបានការស្នើសុំសិទ្ធិអនុញ្ញាតធ្វើប្រតិបត្តិការប័ណ្ណ ឬសេចក្តីជូនដំណឹងអំពីប្រតិបត្តិការប័ណ្ណនៃការស្នើសុំទូទាត់ (មានដូចជាការស្នើសុំតាមមធ្យោបាយអេឡិចត្រូចនិច) បើទោះ បីជាការស្នើសុំ ឬការជូនដំណឹងមិនត្រូវបានអនុញ្ញាត ឬក្លែងបន្លំ ឬប្រតិបត្តិការប័ណ្ណមិនត្រូវបានធ្វើ ឬច្រានចោល។

៩.៩ សមាជិកប័ណ្ណមិនត្រូវកំណត់សិទ្ធិរបស់ខ្លួនក្នុងកិច្ចព្រមព្រៀងនេះឡើយ។

៩.១០ ធនាគារមិនទទួលខុសត្រូវចំពោះការក្លែងបន្លំ ឬប្រតិបត្តិការដែលធ្វើឡើងដោយមិនមានការអនុញ្ញាត ឬការបាត់បង់ ការខូចខាត ឬការទទួលខុសត្រូវដែលបានរ៉ាប់រង និង/ឬទូទាត់ដោយសមាជិកប័ណ្ណក្នុងករណីប្រតិបត្តិការត្រូវបានធ្វើឡើង/មានប្រសិទ្ធភាពដោយសារមេរោគក្នុងកុំព្យូទ័រផ្ទាល់ខ្លួន ឬឧបករណ៍ឆ្លាតវ័យដែលជាកម្មសិទ្ធិ/ប្រើប្រាស់ដោយសមាជិកប័ណ្ណ។ ជាចុងក្រោយ សមាជិកប័ណ្ណធានាអះអាងចាត់វិធានការបង្ការចាំបាច់នានាដើម្បីធ្វើបច្ចុប្បន្នភាព និងការពារកុំព្យូទ័រផ្ទាល់ខ្លួន ឬឧបករណ៍ឆ្លាតវ័យដើម្បីធានាថា កុំព្យូទ័រផ្ទាល់ខ្លួន ឬឧបករណ៍ឆ្លាតវ័យគ្មានមេរោគ។

១០. កម្រៃ និងសោហ៊ុយសេវា

១០.១កម្រៃ និងសោហ៊ុយសេវាលើប្រតិបត្តិការមានដូចខាងក្រោម៖

ល.រ	បរិយាយ	កម្រៃ និងសោហ៊ុយសេវា
១	ធ្វើប្រតិបត្តិការនៅ៖ ក. ម៉ាស៊ីនអេធីអឹម/ម៉ាស៊ីនដកដាក់ប្រាក់ធនាគារកម្ពុ	
	• ពិនិត្យសមតុល្យ	ឥតគិតថ្លៃ
	• របាយការណ៍សង្ខេប	ឥតគិតថ្លៃ
	• ការដកសាច់ប្រាក់	ឥតគិតថ្លៃ
	• ផ្ទេរប្រាក់	ឥតគិតថ្លៃ
	• ទូទាត់បំណុលទាន/ឥណពន្ធ	ឥតគិតថ្លៃ
	• ប្តូរលេខសំងាត់	ឥតគិតថ្លៃ
	ខ. បណ្តាញម៉ាស៊ីនអេធីអឹមសាច់ប្រាក់ងាយស្រួល	
	• ពិនិត្យសមតុល្យ	០,៣០ សេន ដុល្លារអាមេរិក ក្នុងមួយប្រតិបត្តិការ
	• ការដកសាច់ប្រាក់	០,៥០ សេន ដុល្លារអាមេរិក ក្នុងមួយប្រតិបត្តិការ
	គ.មិនមែនបណ្តាញម៉ាស៊ីនអេធីអឹមធនាគារកម្ពុ/បណ្តាញសាច់ប្រាក់ងាយស្រួល	៥ ដុល្លារអាមេរិក ក្នុងមួយប្រតិបត្តិការ
	ឃ. នៅបញ្ជ	
	• ធនាគារកម្ពុ	ឥតគិតថ្លៃ
	• មិនមែនធនាគារកម្ពុ	១% នៃចំនួនទឹកប្រាក់ដែលបានដក ឬយ៉ាងតិច ៥ ដុល្លារអាមេរិក ក្នុងមួយប្រតិបត្តិការ
	ង. ការទិញរាយរងតាម E-POS	ឥតគិតថ្លៃ

១១. ប្រតិបត្តិការ

១១.១លក្ខណៈពិសេសជាស្តង់ដារសម្រាប់ប័ណ្ណអេធីអឹម Proprietary និងប័ណ្ណឥណពន្ធ Visa/Mastercards Lifestyle មានដូចខាងក្រោម៖

ល.រ	បរិយាយ	ប្រភេទប័ណ្ណធនាគារកម្ពុ		
		ប័ណ្ណអេធីអឹម Proprietary	**ប័ណ្ណឥណពន្ធ Visa Lifestyle**	**ប័ណ្ណឥណពន្ធ Mastercard Lifestyle**
១	**ធ្វើប្រតិបត្តិការនៅ៖**			
	ម៉ាស៊ីនអេធីអឹមធនាគារកម្ពុ	✓	✓	✓
	• ពិនិត្យសមតុល្យ	✓	✓	✓
	• របាយការណ៍សង្ខេប	✓	✓	✓
	• ដកសាច់ប្រាក់	✓	✓	✓
	• ផ្ទេរប្រាក់	✓	✓	✓
	• ទូទាត់ប័ណ្ណឥណទាន/ឥណពន្ធ	✓	✓	✓
	• ប្តូរលេខសំងាត់	✓	✓	✓
២	បណ្តាញសាច់ប្រាក់ងាយស្រួល			
	• ដកសាច់ប្រាក់	×	✓	×
	• ពិនិត្យសមតុល្យ	×	✓	×
៣	មិនមែនម៉ាស៊ីនអេធីអឹមធនាគារកម្ពុ និងកម្រៃពីបណ្តាញសាច់ប្រាក់ងាយស្រួល			
	• ដកសាច់ប្រាក់	×	✓	✓
	• ពិនិត្យសមតុល្យ	×	✓	✓
	• ផ្ទេរប្រាក់	×	×	×
	• របាយការណ៍សង្ខេប	×	×	×
	• ប្តូរលេខសំងាត់	×	×	×
៤	ម៉ាស៊ីនឆូតកាតធនាគារកម្ពុនៅ៖			
	ក. សាខា			
	• ដកសាច់ប្រាក់	✓	✓	✓
	ខ. ទំនិញ/ទិញរាយរង			
	• ការទិញរាយរង	✓	✓	✓

៥	មិនមែនម៉ាស៊ីនឆូតកាតធនាគារនៅ៖			
	ក. សាខា			
	• ដកសាច់ប្រាក់	×	✓	✓
	ខ. ទំនិញ/ទិញរាយរង	×	✓	✓
	• ការទិញរាយរង	×	✓	✓
៦	ប្រតិបត្តិការតាមអនឡាញ	×	✓	✓
៧	ប្រតិបត្តិការក្រៅប្រទេស	×	✓	✓

១២. លំនាំដើម

១២.១ កម្រិតលំនាំដើមសម្រាប់ប័ណ្ណអេធីអឹម Proprietary និងប័ណ្ណឥណពន្ធ Visa/Mastercards Lifestyle នៅក្នុងប្រព័ន្ធ មានដូចខាងក្រោម៖

ល.រ	**ប្រភេទប្រតិបត្តិការ**	**កម្រិតលំនាំដើម ប្រចាំថ្ងៃ (ដុល្លារអាមេរិក)**	**កម្រិតលំនាំដើមអតិបរមាមួយ ប្រតិបត្តិការ (ដុល្លារអាមេរិក)**	**ចំនួនប្រតិបត្តិការ ឬ ការរាប់ប្រចាំថ្ងៃក្នុង មួយថ្ងៃតាមលំនាំដើម**
១	ប្រតិបត្តិការអេធីអឹម			
	ការដកសាច់ប្រាក់/ការផ្ទេរប្រាក់ #	១.000	១.000	៥
២	ប្រតិបត្តិការតាមម៉ាស៊ីនឆូតកាត			
	ការដកសាច់ប្រាក់ #	0,00	(១) @	៥
	ការទិញទំនិញរាយរង/អនឡាញ	១,៥00	១,៥00	២0

<u>សេចក្តីពន្យល់</u>

@ ការដកសាច់ប្រាក់នៅតាមម៉ាស៊ីនឆូតកាតត្រូវបានកំណត់តាមលំនាំដើម ឬកំណត់ជា (១) ក្នុងប្រព័ន្ធ Cardzone គឺមានន័យថា មិនអាចប្រើប្រាស់បានទេនៅពេលនេះ។

កម្រិតកំណត់ប្រចាំថ្ងៃសម្រាប់ការដកសាច់ប្រាក់/ការផ្ទេរប្រាក់ និង "នៅបញ្ជ" ការដកសាច់ប្រាក់នៅតាមម៉ាស៊ីនឆូតកាតគឺជាកម្រិត SHARED ឬ COMBINED ។

ប្រសិនបើសមាជិកប័ណ្ណអេធីអឹម Proprietary និងប័ណ្ណឥណពន្ធ Visa/Mastercards Lifestyle មិនត្រូវលក្ខណៈពិសេសអំពីការទិញទំនិញរាយរង/តាមអនឡាញ និងការដកសាច់ប្រាក់ "នៅបញ្ជ" សាខាទទួលបន្ទុកត្រូវបានអនុញ្ញាតឱ្យរក្សាកម្រិតអតិបរមាក្នុងមួយប្រតិបត្តិការក្នុងប្រព័ន្ធ Cardzone គឺ (១) មានន័យថា សេវានេះមិនអាចប្រើប្រាស់បានទេនៅពេលនេះ។

១២.២ កម្រិតដែលអាចបត់បែនបានត្រូវបានអនុញ្ញាតសម្រាប់សាខា ដើម្បីធ្វើបច្ចុប្បន្នកម្ម ជូនសមាជិកប័ណ្ណដែលមានដូចខាងក្រោម៖

ល.រ	**ប្រភេទប្រតិបត្តិការ**	**អនុញ្ញាតចំពោះសំណើសុំកម្រិតខ្ពស់ រហូតដល់ទៅ ៣.០០០ ដុល្លារអាមេរិក**	
		កម្រិតប្រើប្រាស់បានប្រចាំថ្ងៃ	**កម្រិតអតិបរមាក្នុងមួយប្រតិបត្តិការ**
១	ប្រតិបត្តិការអេធីអឹម		
	• ការដកសាច់ប្រាក់/ការផ្ទេរប្រាក់	✓	×
២	ប្រតិបត្តិការតាមម៉ាស៊ីនឆូតកាត		
	• ការដកសាច់ប្រាក់	✓	✓
	• ការទិញទំនិញរាយរង/អនឡាញ	✓	✓

១៣. សេចក្តីជូនដំណឹង

១. សមាជិកប័ណ្ណត្រូវជូនដំណឹងមកធនាគារជាលាយលក្ខណ៍អក្សរ អំពីការផ្លាស់ប្តូរលេខទំនាក់ទំនង និង/ការប្តូរអាសយដ្ឋាន និង/ឬការងារ ឬអាជីវកម្ម។

១៤. ការជូនដំណឹង

សមាជិកប័ណ្ណយល់ព្រមថា ការជូនដំណឹងពាក់ព័ន្ធទៅនឹងការប្តឹងទាមទារដែលផ្តើមចេញពី ឬពាក់ព័ន្ធទៅនឹងកិច្ចព្រមព្រៀងនេះ អាចត្រូវបានធ្វើឱ្យមានប្រសិទ្ធភាព តាមរយៈការបញ្ជូនសេចក្តីជូនដំណឹងដូចគ្នាតាមប្រៃសណីយ៍ទៅកាន់អាសយដ្ឋានចុងក្រោយរបស់សមាជិកប័ណ្ណ ដែលមានបញ្ជាក់ក្នុងពាក្យស្នើសុំប្រើប្រាស់ប័ណ្ណរបស់ធនាគារ ឬទៅកាន់អាសយដ្ឋានផ្សេងទៀតដែលត្រូវបានជូនដំណឹងតាមរយៈសមាជិកមកធនាគារពីពេលមួយទៅពេលមួយ ហើយត្រូវចាត់ទុកថាបានទទួលនៅពេលផ្ញើសេចក្តីជូនដំណឹងនេះ ហើយការបញ្ជូនសេចក្តីជូនដំណឹងនេះមានលក្ខណៈគ្រប់គ្រាន់ក្នុងការបញ្ជាក់ថា សេចក្តីជូនដំណឹងដដែលត្រូវបានទទួលត្រឹមត្រូវ និងបញ្ជូនតាមប្រៃសណីយ៍ បើទោះជាមានភស្តុតាងបញ្ជាក់ផ្សេងពីនេះ។

១៥. ខ បម្រុង

បទប្បញ្ញត្តិណាមួយដែលគ្មានសុពលភាព ឬមិនអាចអនុវត្តបានមិនត្រូវមានអនុភាពលើសុពលភាព និងការអនុវត្ត ខ និងលក្ខខណ្ឌផ្សេងទៀតដែលមាននៅមានសុពលភាពក្នុងកិច្ចព្រមព្រៀងនេះឡើយ។

១៦. ខ និងលក្ខខណ្ឌផ្សេងទៀត

ខ និង លក្ខខណ្ឌដែលមានក្នុងកិច្ចព្រមព្រៀងនេះត្រូវបន្ថែម និងមិនត្រូវធ្វើឱ្យប៉ះពាល់ដល់កិច្ចព្រមព្រៀង ឬការរៀបចំជាក់លាក់បច្ចុប្បន្ន ឬពេលអនាគតដែលបង្កើតឡើងរវាងធនាគារ និងសមាជិកប័ណ្ណ ឬខ និងលក្ខខណ្ឌណាមួយដែលអាចត្រូវបានកំណត់ជាក់លាក់ក្នុងលិខិតផ្តល់ជូន ដែលផ្តល់ជូនដោយធនាគារពីពេលមួយទៅពេលមួយ។

១៧. មោឃៈភាពកិច្ចព្រមព្រៀង

រាល់កិច្ចព្រមព្រៀង ឬការរៀបចំមុនៗ ប្រសិនបើមាន ដែលបានធ្វើឡើងរវាងធនាគារ និងសមាជិកប័ណ្ណ មិនថាធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់ត្រូវចាត់ទុកជាមោឃៈភាពដោយកិច្ចព្រមព្រៀងនេះ។

១៨. ទំនាក់ទំនង

តាមឆន្ទានុសិទ្ធិរបស់ខ្លួន ធនាគារមានសិទ្ធិ (មិនមានកាតព្វកិច្ច) ពឹងផ្អែក និងប្រើប្រាស់ទំនាក់ទំនង ការ ស្នើសុំ ឬការបញ្ជាដែលធនាគារយល់ថា បានមកពីសមាជិកប័ណ្ណ (មិនថាទទួលបានដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ និងមិនថាទទួលដោយផ្ទាល់ ឬតាមរយៈទូរស័ព្ទ ឬតាមទូរសារ ឬមធ្យោបាយទូរគមនាគមន៍ផ្សេងទៀត និងមិនថាតើមាន ឬគ្មានការយល់ព្រម ឬការផ្តល់សិទ្ធិអនុញ្ញាតជាក់ស្តែងរបស់សមាជិកប័ណ្ណ) និងចំណាត់ការណាមួយដែលធនាគារអនុវត្តត្រូវភ្ជាប់កាតព្វកិច្ចសមាជិកប័ណ្ណ ហើយធនាគារមិនទទួលខុសត្រូវចំពោះសមាជិកប័ណ្ណចំពោះការខាតបង់ ឬខូចខាត ដែលបានរ៉ាប់រង ឬទទួលរងដោយសារចំណាត់ការនេះ។ ធនាគារមិនមានករណីកិច្ចផ្ទៀងផ្ទាត់អត្តសញ្ញាណបុគ្គលដែលទំនាក់ទំនងជួសមុខឱ្យ ឬក្នុងនាមជាសមាជិកប័ណ្ណឡើយ។

១៩. សំណង

សមាជិកប័ណ្ណ ត្រូវ សងសំណង និងរក្សា ការសងសំណងជូន ធនាគារ ពេញលេញ លើរាល់សិទ្ធិ លើបំណុល ការទាមទារ ចំណាត់ការ សំណុំរឿងបណ្តឹង ការបាត់បង់ ការខូចខាត ថ្លៃដើម និងការចំណាយក្នុងលក្ខណៈណាមួយ (ក្នុងនោះរួមមានការចំណាយលើផ្លូវច្បាប់សម្រាប់ការសងសំណង) ដែលបានប្រឈម រ៉ាប់រង ឬទ្រទ្រង់ដោយធនាគារដោយផ្ទាល់ ឬដោយប្រយោល ដោយហេតុផល ឬពាក់ព័ន្ធទៅនឹងកិច្ចព្រមព្រៀងនេះ ដោយក្នុងនោះរួមមាន៖

១. ការប្រើប្រាស់ ឬការប្រើប្រាស់ប័ណ្ណខុសគោលដៅ និង/ឬ
២. រំលោភបំពានបទប្បញ្ញត្តិណាមួយនៃកិច្ចព្រមព្រៀងនេះដោយភាគីសមាជិកប័ណ្ណ និង/ឬ
៣. ការអនុវត្ត ឬការការពារសិទ្ធិរបស់ធនាគារ និងការកែតម្រូវលើសមាជិកប័ណ្ណអនុលោមតាមកិច្ចព្រមព្រៀងនេះ